# ពាក្យស្នើសុំសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន Minnesota ឆ្នាំ 2024

**ដាក់ពាក្យសុំតាមអ៊ីនធឺណិត https://www.mnvotes.gov -ឬ-**

**បំពេញជួរទី 1 ដល់ទី 7 ខាងក្រោម។ សូមបោះពុម្ពឱ្យបានច្បាស់។**

សូមប្រគល់ពាក្យស្នើសុំមកវិញឱ្យបានឆាប់តាមដែលអាចធ្វើបាន។ សន្លឹកឆ្នោតត្រូវប្រគល់ត្រឡប់មកវិញនៅត្រឹមថ្ងៃបោះឆ្នោតដើម្បីធ្វើការរាប់។

**ព័ត៌មានសំខាន់៖**យោធាកំពុងជាប់ភារកិច្ចនិងអ្នកបោះឆ្នោតនៅក្រៅប្រទេសមិនគួរប្រើប្រាស់ពាក្យស្នើសុំនេះឡើយ។សូមមើលទំព័រម្ខាងទៀតសម្រាប់ព័ត៌មានបន្ថែម។

**1.** សន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានដែលបានស្នើសុំសម្រាប់ការបោះឆ្នោតខាងក្រោម*(ប្រសិនបើពុំបានគូសការបោះឆ្នោតណាមួយទេសន្លឹកឆ្នោតនឹងត្រូវផ្ញើសម្រាប់តែការបោះឆ្នោតបន្ទាប់ប៉ុណ្ណោះ)*

- ☐ ទាំងការបោះឆ្នោតបឋមនិងការបោះឆ្នោតសកល
- ☐ ការបោះឆ្នោតបឋមតែប៉ុណ្ណោះ
- ☐ ការបោះឆ្នោតសកលតែប៉ុណ្ណោះ
- ☐ ការបោះឆ្នោតបឋមពិសេស - សូមបញ្ជាក់កាលបរិច្ឆេទ ______
- ☐ ការបោះឆ្នោតពិសេស - សូមបញ្ជាក់កាលបរិច្ឆេទ ______

**2.**

| នាមត្រកូល | នាមខ្លួន | នាមកណ្ដាល | បច្ច័យ |
|---|---|---|---|
| | | | |

**3.**

| ថ្ងៃខែឆ្នាំកំណើត (ខែ/ថ្ងៃ/ឆ្នាំ) | ប្រទេសដែលអ្នករស់នៅ | លេខទូរស័ព្ទ |
|---|---|---|
| | | - - |

អាសយដ្ឋានអ៊ីមែល

**4.** សូមគូសប្រអប់ទាំងអស់ដែលពាក់ព័ន្ធ៖

- ☐ ខ្ញុំមានប័ណ្ណបើកបរចេញដោយ MN ឬអត្តសញ្ញាណប័ណ្ណ MN។លេខ៖ ______
- ☐ ខ្ញុំមានលេខសន្តិសុខសង្គម។លេខបួនខ្ទង់ចុងក្រោយគឺ៖ XXX-XX- ______
- ☐ ខ្ញុំពុំមានប័ណ្ណបើកបរចេញដោយ MN អត្តសញ្ញាណប័ណ្ណចេញដោយ MN ឬលេខសន្តិសុខសង្គមទេ។

លេខអត្តសញ្ញាណរបស់អ្នកនឹងត្រូវប្រៀបធៀបជាមួយលេខនៅលើស្រោមសំបុត្រសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន។

**5.**

| អាសយដ្ឋានរស់នៅរបស់អ្នក (គេហដ្ឋាន) | អគារ | ទីក្រុង | | លេខកូដប្រៃសណីយ៍ |
|---|---|---|---|---|
| | | | **MN** | |

**6.**

| អាសយដ្ឋានដែលសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានត្រូវផ្ញើទៅ | អគារ | ទីក្រុង | រដ្ឋ | លេខកូដប្រៃសណីយ៍ |
|---|---|---|---|---|
| | | | | |

**7.** ខ្ញុំសូមបញ្ជាក់ថាខ្ញុំ៖

- កំពុងបំពេញពាក្យស្នើសុំនេះដោយខ្លួនឯង
- នឹងមានអាយុយ៉ាងតិច18ឆ្នាំនៅថ្ងៃបោះឆ្នោត
- គឺជាពលរដ្ឋរបស់សហរដ្ឋអាមេរិក
- នឹងរស់នៅក្នុងរដ្ឋ Minnesota រយៈពេល 20ថ្ងៃមុនថ្ងៃបោះឆ្នោតមកដល់
- នៅតែស្នាក់នៅនៅអាសយដ្ឋានដែលបានផ្តល់ជូននៅលើទម្រង់ចុះឈ្មោះ។
- មិនស្ថិតក្រោមការឃ្លាំមើលតាមបញ្ជាតុលាកាដែលតុលាការបានបញ្ជាឱ្យលុបចោលសិទ្ធិបោះឆ្នោតរបស់ខ្ញុំ។
- តុលាការពុំរកឃើញថាខ្ញុំពុំមានសមត្ថភាពផ្នែកច្បាប់ដើម្បីធ្វើការបោះឆ្នោត
- នៅបច្ចុប្បន្ននេះ ខ្ញុំគឺមិនជាប់ពន្ធនាគារ សំរាប់ការជាប់ទោស នៃការប្រព្រឹត្តិបទឧក្រិដ្ឋឡើយ
- បានអាននិងបានយល់សេចក្តីថ្លែងការណ៍នេះ៖ព័ត៌មានខាងលើពិតជាត្រឹមត្រូវហើយខ្ញុំចុះហត្ថលេខាលើពាក្យស្នើសុំនេះដោយព្រមទទួលពិន័យ ប្រសិនបើមានការផ្តល់សក្ខីភាពមិនពិតបទឧក្រិដ្ឋដាក់ទោសឱ្យជាប់ពន្ធនាគារមិនលើសពី5ឆ្នាំការពិន័យជាទឹកប្រាក់មិនលើសពី$10,000ឬទាំងពីរ។

**សូមចុះហត្ថលេខាត្រង់នេះ៖ X**________________________________ **កាលបរិច្ឆេទ** _____/_____/_____

## សូមមើលទំព័រម្ខាងទៀតសម្រាប់ការណែនាំពិសេសសម្រាប់អ្នកបោះឆ្នោតជាជនពិការឬលិខិតប្រគល់សិទ្ធិ។

official use only

| | | | | | | | |
|---|---|---|---|---|---|---|---|
| Primary → ☐ reg ☐ non-reg | received date | ballot issued date | initials | type M C HCF | reason replaced ☐ rejected ☐ lost ☐ spoiled ☐ never received | repl. date: | precinct |
| General → ☐ reg ☐ non-reg | received date | ballot issued date | initials | type M C HCF | reason replaced ☐ rejected ☐ lost ☐ spoiled ☐ never received | repl. date: | school district |

# សូមប្រគល់ពាក្យស្នើសុំនេះឱ្យបានឆាប់តាមដែលអាចធ្វើបានទៅកាន់៖

### ទីកន្លែងត្រូវប្រគល់ពាក្យស្នើសុំរបស់អ្នក

អ្នកត្រូវប្រគល់ពាក្យស្នើសុំនេះទៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក។ប្រសិនបើពុំមានផ្តល់ជូនខាងលើទេអ្នកអាចស្វែងរកព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកនៅក្នុង "បញ្ជីទំនាក់ទំនងមន្ត្រីបោះឆ្នោត" តាមរយៈវេបសាយត៍ https://www.mnvotes.gov។

### ជម្រើសសម្រាប់ប្រគល់ពាក្យស្នើសុំសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន

សម្រាប់ការបោះឆ្នោតសហព័ន្ធ រដ្ឋ និងទីក្រុង សូមដាក់ពាក្យស្នើសុំសន្លឹកឆ្នោតសម្រាប់ពលរដ្ឋ អវត្តមានតាមអនឡាញតាមរយៈវេបសាយត៍ https://www.mnvotes.gov -ឬ- ពាក្យស្នើសុំសន្លឹកឆ្នោត សម្រាប់ពលរដ្ឋអវត្តមានអាចផ្ញើមកវិញតាមការផ្ញើសំបុត្រ ទូរសារ ឬជាឯកសារស្កែនភ្ជាប់នៅក្នុងអ៊ីមែល។

### ពេលវេលាផ្ញើសន្លឹកឆ្នោតរបស់អ្នក

ឯកសារសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានរបស់អ្នកនឹងផ្ញើជូនអ្នកយ៉ាងតិចចំនួន46ថ្ងៃមុនថ្ងៃបោះឆ្នោត (មិនរាប់បញ្ចូលការបោះឆ្នោតក្រុងដែលធ្វើឡើងនៅក្នុងខែមីនាដែលឯកសារត្រូវផ្ញើជូនរយៈពេល30ថ្ងៃមុនថ្ងៃបោះឆ្នោត)។ ប្រសិនបើអ្នកដាក់ពាក្យសុំនៅក្រោយកាលបរិច្ឆេទនេះសន្លឹកឆ្នោតរបស់អ្នកនឹងត្រូវផ្ញើជូននៅពេលបានទទួលពាក្យស្នើសុំ។សូមទាក់ទងមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកប្រសិនបើអ្នកពុំបានទទួលសន្លឹកឆ្នោតរបស់អ្នក។សូមពិនិត្យមើលស្ថានភាពសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានរបស់អ្នកតាមវេបសាយត៍ https://www.mnvotes.gov។

### កំណត់សម្គាល់អំពីឯកជនភាព

Yថ្ងៃខែឆ្នាំកំណើតពិតប្រាកដអាសយដ្ឋានអ៊ីមែលរបស់អ្នកនិងលេខអត្តសញ្ញាណដែលអ្នកផ្តល់ជូន (ប័ណ្ណបើកបរ Minnesota លេខសម្គាល់រដ្ឋឬលេខបួនខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គម)នឹងត្រូវរក្សាជាព័ត៌មានឯកជន។ មានតែមន្ត្រីបោះឆ្នោតប៉ុណ្ណោះដែលអាចចូលមើលបាន។

មន្ត្រីបោះឆ្នោតស្នើសុំថ្ងៃខែឆ្នាំកំណើតពិតប្រាកដរបស់អ្នកដើម្បីពួកគេអាចដាក់ពាក្យស្នើសុំរបស់អ្នកឱ្យត្រូវជាមួយកំណត់ត្រាអ្នកបោះឆ្នោតរបស់អ្នក។ ប្រសិនបើមិនព្រមផ្តល់ថ្ងៃខែឆ្នាំកំណើតរបស់អ្នកទេអ្នកនឹងមិនទទួលបានសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានឡើយ។

មន្ត្រីបោះឆ្នោតស្នើសុំអ៊ីមែលរបស់អ្នកដើម្បីពួកគេអាចទាក់ទងទៅអ្នកអំពីពាក្យស្នើសុំរបស់អ្នក។ជាមួយគ្នានេះដែរការិយាល័យលេខាធិការរដ្ឋអាចអ៊ីមែលទៅអ្នក (ឬទាក់ទងអ្នកតាមមធ្យោបាយផ្សេងទៀត) អំពីការបោះឆ្នោតឬស្នើសុំមតិយោបល់សាធារណៈ។ប្រសិនបើអ្នកមិនព្រមផ្តល់អាសយដ្ឋានអ៊ីមែលទេអ្នកមិនអាចដាក់ពាក្យស្នើសុំសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានតាមអនឡាញឡើយហើយអ្នកចាំបាច់ត្រូវដាក់ពាក្យស្នើសុំតាមរយៈឯកសារផ្ទាល់។

មន្ត្រីបោះឆ្នោតស្នើសុំលេខអត្តសញ្ញាណដើម្បីពិនិត្យមើលថាបុគ្គលដែលកំពុងបោះឆ្នោតនិងបុគ្គលដែលបានដាក់ពាក្យស្នើសុំគឺជាមនុស្សតែម្នាក់។ប្រសិនបើអ្នកមានលេខអត្តសញ្ញាណប៉ុន្តែបដិសេធពុំព្រមផ្តល់នោះសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានរបស់អ្នកអាចនឹងត្រូវបដិសេធចោលហើយអ្នកនឹងមិនអាចពិនិត្យមើលស្ថានភាពសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានរបស់អ្នកតាមអនឡាញឡើយ។

ទិន្នន័យផ្សេងទៀតនៅលើពាក្យស្នើសុំនឹងត្រូវបង្ហាញជាសាធារណៈនៅពេលប្រើប្រាស់សម្រាប់ការបោះឆ្នោតគោលបំណងនយោបាយឬការអនុវត្តច្បាប់។ប្រសិនបើអ្នកចង់រក្សាព័ត៌មានទំនាក់ទំនងរបស់អ្នកជាការសម្ងាត់នៅក្រោមហេតុផលបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនសូមទូរស័ព្ទទៅលេខ 1-877-600-8683 ដើម្បីទទួលព័ត៌មានអំពីអ្វីដែលអ្នកគួរធ្វើ។

### អ្នកអាចដាក់ពាក្យស្នើសុំសន្លឹកឆ្នោត

បុគ្គលម្នាក់ៗអាចដាក់ពាក្យស្នើសុំដោយខ្លួនឯង។ការធ្វើសេចក្តីថ្លែងមិនពិតនៅក្នុងពាក្យស្នើសុំសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តការព្យាយាមបោះឆ្នោតលើសន្លឹកមិនស្របច្បាប់ឬការជួយនរណាម្នាក់ក្នុងការបោះឆ្នោតលើសន្លឹកមិនស្របច្បាប់គឺជាបទឧក្រិដ្ឋ។

### ប្រសិនបើអ្នកគិតថាអ្នកអាចនឹងមិនបានចុះឈ្មោះបោះឆ្នោត

ប្រសិនបើអ្នកមិនបានចុះឈ្មោះនៅអាសយដ្ឋានស្នាក់នៅស្របច្បាប់ដែលបានផ្តល់ជូនអ្នកនឹងទទួលបានពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោតជាមួយនឹងឯកសារសន្លឹកឆ្នោតរបស់អ្នក។

### ព័ត៌មានសម្រាប់យោធាកំពុងជាប់ភារកិច្ចនិងអ្នកបោះឆ្នោតនៅក្រៅប្រទេស

ប្រសិនបើអ្នកកំពុងដាក់ពាក្យស្នើសុំសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តដោយសារអ្នកឬគ្រួសាររបស់អ្នកគឺជាយោធាកំពុងជាប់ភារកិច្ចឬដោយសារអ្នកនឹងត្រូវចាកចេញទៅក្រៅប្រទេសនិង/ឬក្រៅដែនដីសហរដ្ឋអាមេរិកសូមកុំប្រើប្រាស់ពាក្យស្នើសុំនេះ។អ្នកមានសិទ្ធិទទួលបានការការពារពិសេសប្រសិនបើអ្នកដាក់ពាក្យស្នើសុំដោយប្រើប្រាស់ពាក្យស្នើសុំប័ណ្ណប្រៃសណីសហព័ន្ធ។ សម្រាប់ព័ត៌មានបន្ថែមនិងដើម្បីដាក់ពាក្យស្នើសុំតាមអនឡាញសូមចូលទៅកាន់វេបសាយត៍ https://www.mnvotes.gov។

### ជម្រើសដែលមានសម្រាប់អ្នកប្រសិនបើអ្នកជាជនពិការ

អ្នកអាច៖

- ចុះហត្ថលេខាលើពាក្យស្នើសុំដោយខ្លួនឯង
- ដាក់សញ្ញារបស់អ្នកឬ
- ឱ្យអ្នកផ្សេងជួយចុះហត្ថលេខាជំនួសអ្នកនៅចំពោះមុខអ្នក (ឱ្យបុគ្គលនោះចុះហត្ថលេខាដាក់ឈ្មោះរបស់ខ្លួនឯងផងដែរ)
- ប្រសិនបើអ្នកប្រើប្រាស់ត្រាហត្ថលេខាសម្រាប់គ្រប់ការចុះហត្ថលេខាអ្នកអាចប្រើប្រាស់ត្រាហត្ថលេខារបស់អ្នកឬឱ្យបុគ្គលផ្សេងប្រើប្រាស់ត្រាហត្ថលេខារបស់អ្នកនៅចំពោះមុខអ្នក។(សូមមើល*លក្ខខន្តិកៈ Minnesota* ផ្នែក645.44 អនុផ្នែក14.)

### ព័ត៌មានពាក់ព័ន្ធនឹងលិខិតផ្ទេរសិទ្ធិ

លិខិតផ្ទេរសិទ្ធិមិនអាចប្រើប្រាស់នៅក្នុងការបោះឆ្នោតឡើយ។លិខិតផ្ទេរសិទ្ធិពាក់ព័ន្ធតែទៅនឹងកិច្ចការដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិតែប៉ុណ្ណោះ។ បុគ្គលដែលមានលិខិតផ្ទេរសិទ្ធិអាចត្រឹមតែចុះហត្ថលេខាជំនួសអ្នកនៅចំពោះមុខអ្នកតែប៉ុណ្ណោះដូចដែលបានលើកឡើងខាងលើ។(សូមមើល*លក្ខខន្តិកៈ: Minnesota* ផ្នែក523.24 អនុផ្នែក14.) តែប៉ុណ្ណោះដូចដែលបានលើកឡើងខាងលើ។ (សូមមើល*លក្ខខន្តិកៈ: Minnesota* ផ្នែក523.24 អនុផ្នែក14.)